ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច
Ministry of National Assembly-Senate Relations and Inspection

លេខ : ០៤៦/០៥ ទ.រ.ព.អ ប្រ.ក

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៥

# ប្រកាស

## ស្ដីពី

## ការបង្កើត មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ខេត្ត ព្រៃវែង

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច
- តាមការចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើត **មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ខេត្ត ព្រៃវែង** ជាខ្សែបណ្ដោយរបស់ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ។

**ប្រការ ២ :** មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត ព្រៃវែង ជាសេនាធិការ របស់ក្រសួង ក្នុងការដឹកនាំ គ្រប់គ្រងរាល់កិច្ចការសម្របសម្រួល ធ្វើទំនាក់ទំនងជាមួយអគ្គលេខាធិការរដ្ឋសភា-ព្រឹទ្ធសភា និង អាជ្ញាធរខេត្ត និងធ្វើអធិការកិច្ចលើគ្រប់វិស័យ ក្នុងរង្វង់ដែនដីដែលខ្លួនតាំងនៅ ដើម្បីទប់ស្កាត់ទីង អំពើពុករលួយ ការរំលោភដោយអំណាច និង បាតុភាពអសកម្មនានា ។

**ប្រការ ៣ :** មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត ព្រៃវែង ត្រូវបានដឹកនាំដោយ ប្រធាន ០១ រូប និង អនុប្រធាន មួយចំនួនជាជំនួយការតាមការចាំបាច់ ។ ប្រធាន និង អនុប្រធាន ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួង ។

**ប្រការ ៤ :** រចនាសម្ព័ន្ធគ្រប់គ្រងរបស់ មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ខេត្ត ព្រៃវែង មានការិយាល័យ ចំណុះចំនួន ០៣ :

**១- ការិយាល័យ រដ្ឋបាល-កិច្ចការទូទៅ**

**២- ការិយាល័យ ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អាជ្ញាធរខេត្ត**

**៣- ការិយាល័យ អធិការកិច្ច**

**ប្រការ ៥ :** ការិយាល័យនីមួយៗរបស់ មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ខេត្ត ព្រៃវែង ត្រូវបានដឹកនាំដោយប្រធាន ០១រូប និងអនុប្រធាន មួយចំនួនជាជំនួយការតាមការចាំបាច់ ។ ប្រធាន និង អនុប្រធាន ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួង ។

**ប្រការ ៦ :** តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ។

**ប្រការ ៧ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ :** នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក គ្រប់ប្រធាននាយកដ្ឋានក្រោមឱវាទក្រសួង និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្ត ព្រៃវែង ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ម៉ែន_សំអន**

*កន្លែងទទួល :*

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*-រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ*

*-សាលាខេត្ត ព្រៃវែង*

*" ដើម្បីជូនជ្រាបជាពតិមាន "*

*-ដូចក្នុងប្រការ ៨*

*-ឯកសារ-កាលប្បវត្តិ*